# របាយការណ៍
# ស្តីពីទីតាំងវាលពិឃាត និង ការស្វែងរកបញ្ជីអ្នកទោស
# នៅខេត្តស្វាយរៀង ពីថ្ងៃទី១៧-១៩ ខែសីហា ឆ្នាំ២០០០

---

ដោយ ផេង ពង្សរ៉ាស៊ី

កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០០ ក្រុមស្រាវជ្រាវមួយក្រុម[1] នៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើដំណើរតាមរថយន្តទៅកាន់ខេត្តស្វាយរៀង ក្នុងគោលបំណងឆ្ពោះទៅកាន់ ស្រុក ចំនួនពីរគឺ ស្រុកកំពង់រោទ៍ និង ស្រុករមាសហែក ។

## ស្រុកកំពង់រោទ៍ លេខកូតភូមិសាស្រ្ត ២០០១

ស្រុកកំពង់រោទ៍កាលពីជំនាន់ខ្មែរក្រហមគឺស្ថិតនៅក្នុងតំបន់២៣ ភូមិភាគបូព៌ា ហើយមានឈ្មោះថាស្រុកកំពង់រោទ៍ដដែល ។

ក្រោយ ពីបានទំនាក់ទំនងជាមួយការិយាល័យទំនាក់ទំនងសាធារណៈនៃសាលាខេត្តនៅវេលាម៉ោង២ៈ១៥នាទីរួចមក ក្រុមស្រាវជ្រាវយើងបានធ្វើដំណើរបន្តពីទីរួមខេត្តស្វាយរៀងឆ្ពោះទៅកាន់ស្រុកកំពង់រោទ៍តាមផ្លូវជាតិលេខ១ (ផ្លូវស្វាយរៀង-បាវិត) ។ គោលបំណងគឺស្វែងរកជួបជាមួយលោកអ៊ឹមាស ជនដែលជាអ្នកកាន់បញ្ជីអ្នកទោសក្នុងពេលដែលគាត់នៅក្នុងមន្ទីរសន្តិសុខវត្ត ឫស្សីសាញ់ក្នុងរបបខ្មែរក្រហម ។ នៅវេលាម៉ោង៣ៈ២៥នាទី ក្រុមយើងបានជួបជាមួយគាត់ដោយចៃដន្យនៅតាមផ្លូវលំមួយចំងាយប្រហែលជាងកន្លះគីឡូម៉ែត្រពីផ្ទះរបស់គាត់ ពេលដែលគាត់កំពុងជិះកង់ដើររកជួលអ្នកស្ទូង[2] ។ នៅពេលដែលគាត់បានជួបជាមួយយើង គាត់ហាក់ដូចមាន អារម្មណ៍ភ័យតក់ស្លុតយ៉ាងខ្លាំង សូម្បីតែឈរនិយាយជាមួយយើងក៏គាត់ដោះស្បែកជើងចេញ ដែរ ។

---

[1] ក្រុមស្រាវជ្រាវរួមមានលោកស៊ិន ឃិន និន ទ្រី លី សុផល អ៊ូច សំអឿន ផេង ពង្សរ៉ាស៊ី និងអ្នកកាសែតជនជាតិហូឡង់ម្នាក់ព្រមទាំងមិត្តភក្រ័ពីររូបទៀត ។

[2] បានជួបមាស ផន នៅតាមផ្លូវក្នុងសំលៀកបំពាក់ជាអ្នកធ្វើស្រែ ដោយសារលោកអ៊ឹស៊ិន ឃិនបានស្គាល់ភិនភាគ របស់គាត់ខ្លះៗព្រោះគាត់ធ្លាប់ស្គាល់កាលពីជំនាន់ប៉ុលពត ។

ស្បែកជើងដែលដោះចេញនោះគឺគាត់បានឈរពីលើវា(ស្បែកជើង) ព្រមជាមួយនឹងអាការៈ គោរព ។ ក្រោយពីបានសាកសួរខ្លះៗមក ទើបយើងដឹងថាគាត់មានឈ្មោះ មាស ផន អាយុ៦១ ឆ្នាំ មានស្រុកកំណើតនៅភូមិសំឡី ឃុំសំឡី ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ហើយបច្ចុប្បន្ន គាត់ក៏មានទីលំនៅនៅភូមិ-ឃុំ ស្រុកខាងលើនេះដដែល ។ ផ្ទះរបស់លោកមេភូមិ តាប៉ៅ ក្លាយជាកន្លែងដែលលោកអ៊ំមាស ផនសុំធ្វើសេចក្តីសម្ភាសន៍ជាមួយក្រុមស្រាវជ្រាវ យើង ។ លោកអ៊ំបាននិយាយប្រាប់យើងថាគាត់គ្រាន់តែជាប្រធានក្រុមនារីដឹកនាំខាងបន្ក បង្កើនផល និងដាក់បាយជ្រូកប៉ុណ្ណោះ ។ ក្រុមនារីចំនួន១២នាក់ស្ថិតនៅក្រោមការដឹកនាំរបស់គាត់ (មាស ផន) ។ នៅឆ្នាំ១៩៧៥ លោកអ៊ំគឺជាយោធារបស់ខ្មែរក្រហម ។ កាលនោះលោកអ៊ំមាន ប្រពន្ធនិងកូនបួននាក់ ។ លុះដល់ឆ្នាំ១៩៧៦ លោកអ៊ំធ្វើជាប្រធានក្រុមនារីបន្កបង្កើនផលដែលមាន កិច្ច ការស្ទូងស្រូវច្រូត ស្រូវនៅឃុំព្រៃធំ ស្រុកកំពង់រោទ៍ ។ នៅចុងឆ្នាំ១៩៧៦ លោកអ៊ំត្រូវបាន ផ្លាស់មកធ្វើការខាងកងដឹកជញ្ជូនវិញ ដោយមានគោមួយនឹមនិងរទេះមួយសំរាប់ដឹកស្រូវ ។ លោកអ៊ំបានរត់ទៅរស់នៅជាមួយគ្រួសាររបស់គាត់នៅឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីឆ្នាំ១៩៧៧ ដោយសារមូលហេតុគាត់លួចរត់ចេញពីគុកនៅស្រុកស្វាយជ្រំ បន្ទាប់ពីគាត់ (មាស ផន) ត្រូវបានចាប់ខ្លួនដោយពួកនិរតីកាលពីដើមឆ្នាំ១៩៧៧ ។ ការងាររបស់លោកអ៊ំនៅទីនោះគឺគ្មានអ្វីក្រៅពីធ្វើស្រែ និង កាស់គល់ឈើឡើយ ។ លោកអ៊ំបានប្រាប់ថាគុកឫស្សីសាញ់មានមេសន្តិសុខធំឈ្មោះ ពេជ្រ សារឿន ព្រមទាំងអ្នកក្រោមបញ្ជាពីរ-បីនាក់ទៀតដែលមានឈ្មោះ ដួប បូ និងរ៉ន ។ លោកអ៊ំបានរំលឹកថាៈ «ខ្ញុំអត់មានសៀវភៅអ្នកទោសទេ ព្រោះក្រោយពេលបែកខ្ញុំរត់យករួចតែខ្លួនគ្មានបានយកអ្វីមកជាមួយទេ» ។ លោកអ៊ំត្រូវបានការពារដោយប្រធានភូមិ តាប៉ៅ ព្រមទាំងប្រជារាស្ត្រមួយចំនួនទៀត នៅពេលដែលក្រុមយើងកំពុងធ្វើការសម្ភាសន៍ជាមួយ គាត់ថាគាត់(មាស ផន) ពុំបានធ្វើជាអ្នកបែងចែកអ្នកទោសកាលពីជំនាន់ប៉ុលពតទេ ហើយក៏មិន មែនជាអ្នកកាន់បញ្ជីអ្នកទោសដែរ ។ ចំណែកខ្លួនគាត់(មាស ផន) ក៏បានប្រកែកដូច្នេះដែរនូវរាល់ សំណួរដែលទាក់ទងពីបញ្ហាសៀវភៅនេះ ។ មីងសេក សុខុន អាយុ៤៥ឆ្នាំ មានស្រុកកំណើតនិង បច្ចុប្បន្នរស់នៅភូមិតាប៉ៅ ឃុំសំឡី ស្រុកកំពង់រោទ៍បានបញ្ជាក់ថា «ខ្ញុំស្គាល់តាផនតាំងពីជំនាន់ ប៉ុលពតម៉្លេះហើយកាលនោះគាត់មិនមែនជាសន្តិសុខគុកទេ ហើយក៏មិនមែនជាអ្នកចាត់ចែងអ្នក ទោសដែរ គាត់គ្រាន់តែជាអ្នកគ្រប់គ្រងកងនារីបន្កបង្កើនផលមិនឲ្យរត់ ព្រោះបើកាលណារត់ គាត់(ផន) នឹងត្រូវជាប់គុកជំនួសវិញ» ។

ទោះជាមានការការពារពីប្រជាជនដែលរស់នៅក្បែរៗភូមិរបស់គាត់យ៉ាងណាក៏ដោយ ក៏ប៉ុន្តែសារជាតិពិតរបស់តាផន កាលពីជំនាន់ខ្មែរក្រហមមិនត្រូវបានលាក់បាំងជិតដោយប្រជាជនមួយក្រុមតូចនោះឡើយ ។ យោងតាមសំដីជាច្រើននាក់របស់ជនរងគ្រោះ ក៏ដូចជាអ្នកដឹងឮដទៃ ទៀត ជាពិសេសអ្នកភូមិនៅភូមិតាកឹង ឃុំព្រៃធំ ស្រុកកំពង់រោទ៍ បានប្រាប់ថាតាផន ជាមនុស្ស អាក្រក់ ឃោរឃៅ ។ មើលទៅរូបរាងខាងក្រៅរបស់គាត់(មាស ផន) ហាក់សមនឹងពាក្យថាជាជន ស្លូតត្រង់ បេះដូងសង្គ្រោះប្រជាជនមួយចំនួនកាលពីជំនាន់ប៉ុលពតដោយឲ្យជាអង្ករ និងថ្នាំពេទ្យ ពិតៗ ព្រោះគាត់មានរូបរាងតូច ស្ដើង ទាបទ្រនាប់ មុខមាត់ស្លូតបូត សម្បុរស្រអែម សក់ស្កូត(សក់ល្បាយអាចម៍ខ្លា) ច្រមុះស្រួច... ។ ប៉ុន្តែការពិតត្រូវបានបង្ហាញឲ្យឃើញពីសកម្មភាពរបស់គាត់ក្នុងអំឡុងឆ្នាំ១៩៧៥-៧៨ ពីសំណាក់ជនរងគ្រោះ ។ លោកអ៊ំ ម៉ី សាម៉ុល ជាជនរងគ្រោះផ្ទាល់ដែលបានឃើញសកម្មភាពច្បាស់របស់មាស ផន កាលពីដើមឆ្នាំ១៩៧៦ ដល់ចុង ឆ្នាំ១៩៧៨ ។ ម៉ី សាម៉ុលបានពន្យល់ប្រាប់យើងថាមាស ផនតាមពិតមានតួនាទីពីរគឺ ទីមួយជាអ្នកបែងចែកអ្នកទោសតាមប្រភេទធ្ងន់និងស្រាល និងទីពីរជាអ្នកគ្រប់គ្រងនារីខាងបង្កបង្កើនផល ឬគ្រប់គ្រងអ្នកទោសធុនស្រាល ។ មាស ផនធ្វើការនៅមន្ទីរសំប៉ប ជាមួយសមមិត្ត បូ តាំងពីឆ្នាំ១៩៧៥រហូតដល់ឆ្នាំ៧៨ ។ លោកអ៊ំ សាម៉ុលបានមានប្រសាសន៍ថា “តាផនជាមនុស្សមិនល្អទេ” ព្រោះកាលនោះ(ជំនាន់ប៉ុលពត) មានសៀវភៅមួយក្បាលសំរាប់កត់ត្រាឈ្មោះអ្នកទោសទាំងធ្ងន់ និងស្រាល ហើយក៏ជាសៀវភៅសំរាប់បែងចែកអ្នកទោសតាមប្រភេទដែរ ។ សៀវភៅដែល មាស ផនកាន់នោះមានកំរាស់ប្រហែល២-៣ហ៊ុន បណ្ដោយប្រហែល២តឹក និងទទឹងប្រហែល ១,៥តឹក ។ បញ្ជីនោះមានក្របខាងក្រៅរឹង ពណ៌ខ្មៅ ព្រមទាំងមានឈ្មោះអ្នកទោសប្រហែលរាប់ ពាន់នាក់ ។ ម៉ី សាម៉ុលបានរាយការណ៍ថា មាស ផន បានហៅអ្នកទោសមកសួរចម្លើយរួមជាមួយនឹងការវាយតប់ផងហើយប្រភេទអ្នកទោសធ្ងន់និងស្រាលស្រេចតែលើគាត់ជាអ្នកសម្រេច ។ អ្នកទោសស្រាលមាស ផន ជាអ្នកគ្រប់គ្រងដោយផ្ទាល់នៅមន្ទីរសំប៉ប(អ្នកទោសស្រាលសុទ្ធជា នារី) ចំណែកអ្នកទោសធ្ងន់ត្រូវបានបញ្ជូនទៅកាន់មន្ទីរសន្តិសុខឫស្សីសាញ់ដែលមានឈ្មោះ កែច ជាអ្នកគ្រប់គ្រងដោយផ្ទាល់ ។ ម៉ី សាម៉ុលនិយាយថា “អ្នកណាក៏ដោយ ឲ្យតែចូលដល់ដៃរបស់ តាផនហើយ គឺគ្មានអ្នកណាមានជីវិតរស់នៅឡើយ” ។ មាស ផន នៅមានតួនាទីមួយទៀតគឺ ទទួលចុះឈ្មោះប្រជាជនដែលត្រូវបានរាយការណ៍ពីប្រធានភូមិ-ឃុំ ឬ ប្រធានសហករណ៍ថាជា

មនុស្សខ្ជីលច្រអូស ក្បត់បដិវត្តន៍ ហ៊ាននិយាយដើមអង្គការពេលយប់ ។ ក្រោយពេលទទួល សេចក្តីរាយការណ៍ និងក្រោយពេលចុះឈ្មោះនៅ ក្នុងបញ្ជីរបស់គាត់ហើយ មាស ផននឹងចាត់ វិធានការភ្លាមនៅថ្ងៃបន្ទាប់ ។ វិធានការនោះគឺមាស ផនបានកាន់បញ្ជីនោះទៅតាមខ្លួនរួចបើកបញ្ជីនោះហៅឈ្មោះអ្នកនោះយកមកដាក់គុកដោយគ្មានសួរនាំអ្វីឡើយ ។ ម្យ៉ាងទៀតនៅពេលដែល មាស ផនបានទទួលលិខិតពីប្រធានមន្ទីរសន្តិសុខស្រុកកំពង់រោទ៍ឈ្មោះសមមិត្តពេជ្រ សារឿនរួច មកមាស ផនបានអនុវត្តន៍តាមលិខិតនោះភ្លាមគឺចាត់ឲ្យកូនចៅរបស់ខ្លួនទៅបណ្តើរអ្នកទោសដែល

បានចាប់នៅតាមបណ្តាឃុំភូមិផ្សេងៗ ជុំវិញស្រុកមកធ្វើការបែងចែកតាមប្រភេទធ្ងន់និងស្រាល ។ មុំ ពីងជាប្រជាជនរស់នៅក្បែរផ្ទះរបស់ម៉ី សាម៉ុលបាននិយាយថា “ទោសធ្ងន់ និងស្រាលគឺអាស្រ័យនៅលើមាត់របស់តាផនតែម្នាក់គត់” ។ ប៉ុន្តែមុំ ពីងក៏បានប្រាប់បន្តថាអ្នកដែលមានទោសធ្ងន់គឺជាប្រភេទមនុស្សដែលក្បត់នឹងអង្គការ ហ៊ានប្រឆាំងនឹងអង្គការ ដូចជាក្រុមខ្មែរសជាដើម ។ ចំណែកអ្នកទោសស្រាលគឺជាប្រភេទមនុស្សដែលខុសសំដី ។ មុំ ពីងបានបន្តថាទោះជាយ៉ាងនេះ ក៏ដោយ មាស ផន នៅតែបែងចែកឲ្យប្រុសៗទៅជាអ្នកទោសប្រភេទធ្ងន់ ហើយស្រីៗជាប្រភេទ អ្នកទោសស្រាល ។ ក្រៅពីការងារទាំងនេះមាស ផននៅបានបញ្ជាឲ្យសមមិត្ត កែប ជាអនុប្រធានគុកបុស្សឫស្សីសាញ់យកមនុស្សទៅសម្លាប់ ។

បញ្ជីដែល មាស ផន ប្រើប្រាស់សំរាប់បែងចែកអ្នកទោសនោះមិនបានផ្លាស់ប្តូរថ្មីទេ ។ កាបូបខ្មៅធំមួយដែលទំនងជាមានឯកសារពេញត្រូវបាននាំយកជាប់ជាមួយនឹងខ្លួនមាស ផននៅពេលដែលរត់គេចខ្លួនឆ្ពោះមកទិសខាងលិច(អ្នកលឿង) នៅចុងឆ្នាំ១៩៧៧ដោយសារការវាយលុករបស់កងទ័ពវៀតណាម ។ ម៉ី សាម៉ុលបាននិយាយថា កាបូបខ្មៅនោះពិតជាមានបញ្ជីអ្នកទោស ។ មូលហេតុដែលមាស ផននាំយកឯកសារ-បញ្ជីទាំងនោះទៅជាមួយ ព្រោះគាត់(តាផន) ខ្លួនឯងយល់ថាពិតជានៅមានអនាគតស្ថិតស្ថេរទៅថ្ងៃមុខ ។ តាំងពី ថ្ងៃនោះមកម៉ី សាម៉ុល ពុំដែលបានដំណឹងថាតើមាស ផនរស់ ឬស្លាប់ឡើយរហូតមកដល់ថ្ងៃដែលក្រុមយើងបានសម្ភាសន៍ជាមួយគាត់ នេះ ។ ប្រជាជនភាគច្រើននៅក្នុងឃុំព្រៃធំនៅមានគំនុំគំគួនជាមួយមាស ផនយ៉ាងខ្លាំងព្រោះអ្នកស្រុកអ្នកភូមិយល់ថាមាស ផនជាមនុស្សកាចសាហាវបំផុតបន្ទាប់ពីឈ្មោះ សារ៉ន និង ពេជ្រ សារឿនដែលជាថ្នាក់ដឹកនាំរបស់មាស ផនផ្ទាល់ ។ អ្នកមីងអន្តុយលក់បបរ(មិនស្គាល់ឈ្មោះ)

តាមចិញ្ចើមផ្លូវម្នាក់បាននិយាយថា «តាផន ឲ្យតែហ៊ានចូលមកកន្លែងនេះ ប្រាកដជាត្រូវកាប់ចិញ្ច្រាំដូចប្រហុកអញ្ចឹង» ។

ដើម្បីឲ្យកាន់តែច្បាស់នូវហេតុផលជុំវិញបញ្ហាបញ្ជីអ្នកទោសកាលពីជំនាន់ខ្មែរក្រហម ដែលបានកាន់កាប់ដោយ តាផននោះ សូមអាននូវសំដីផ្ទាល់របស់មាស ផន និង ជនរងគ្រោះផ្សេងទៀតដែលបានបកស្រាយតាមការយល់ដឹងរៀងៗខ្លួនដូចខាងក្រោមនេះ ។

## កិច្ចសម្ភាសន៍ជាមួយ មាស ផន

មាស ផនអាយុ៦១ឆ្នាំ មានស្រុកកំណើតនៅភូមិសំឡី ឃុំសំឡី ស្រុកកំពង់រោទ៍ ខេត្ត ស្វាយរៀង ។ បច្ចុប្បន្ននៅហ្នឹងដែរ ។ កាលពីជំនាន់ប៉ុលពតក៏រស់នៅទីនេះដែរ ។ កាលនោះ(ប៉ុល ពត) ខ្ញុំមាននាទីជាប្រធានក្រុមខាងបង្កបង្កើនផលនៅជាមួយនារី ។ ក្រោយមកទៀតពីឆ្នាំ១៩៧៧ គេដកហូតចេញពីកងនារីឲ្យមកខាងដឹកជញ្ជូន ដោយគ្មានតួនាទីអីទេ ។ ក្រោយពីចេញពីដឹកជញ្ជូនមក គេឲ្យទៅនៅស្រុកស្វាយរៀង ព្រោះមានពួកនិរតីចូលមកចាប់ ។ ខ្ញុំគ្មានបានធ្វើការខាងបែងចែកអ្នក ទោសធ្ងន់ឬស្រាលទេ ខ្ញុំគ្រាន់តែជាអ្នកទទួលខាងបង្កបង្កើនផលសំរាប់ដឹកនាំនារីឲ្យទៅស្ទូងនៅឃុំ ព្រៃធំ ស្រុកកំពង់រោទ៍ ។ ខាងប្រុសៗ មានឈ្មោះសារ៉ន បូ ជាអ្នកកាន់កាប់ ។ មេសន្តិសុខនៅ បុស្សឫស្សីសាញ់ឈ្មោះតាពេជ្រ សារឿន ។ ខ្ញុំអត់បានទៅធ្វើការនៅក្នុងគុកបុស្សឫស្សីសាញ់ទេ គឺនៅជា មួយនារីរហូត ។ នៅស្រុកកំពង់រោទ៍ ប៉ុលពតគ្រប់គ្រងតាំងពីឆ្នាំ១៩៧៥ ។ កាលនោះខ្ញុំជា យោធាខ្មែរក្រហមក្នុងអាយុជាង៤០ឆ្នាំ ខ្ញុំមានប្រពន្ធនិងមានកូន៤នាក់ ស្រី២ប្រុស២ ។ ក្រោយ មកទៀតគេយកមកធ្វើជាប្រធានក នារីគ្រប់គ្រងផ្នែកនារីមួយក្រុម ។ កិច្ចការរបស់ក្រុមនារីគឺស្ទូង និង ច្រូតនៅឃុំព្រៃធំ ស្រុកកំពង់រោទ៍ ។ ក្រោយមកទៀតនៅចុងឆ្នាំ១៩៧៦ ខ្ញុំផ្លាស់មកធ្វើការ នៅកងដឹកជញ្ជូនវិញមានគោមួយនឹមរទេះមួយសំរាប់ដឹកស្រូវ ។ ចំណែកគុកបុស្សឫស្សីសាញ់មាន ឈ្មោះពេជ្រ សារឿនជាប្រធាន ឈ្មោះដួប ឈ្មោះបូ និង សារ៉នធ្វើការនៅទីនោះ ។ ខ្ញុំអត់មាន សៀវភៅអ្នកទោសទេ ព្រោះក្រោយពេលបែកខ្ញុំរត់រក្សួចតែខ្លួនគ្មានបានយកអ្វីមកជាមួយទេ ។ នៅឆ្នាំ១៩៧៧ ខ្ញុំជាមួយគ្រួសារបានជម្លៀសមកកាន់ស្រុកកៀនស្វាយ ខេត្តកណ្តាល ក្នុងឃុំ សំរោងធំ ។ ទៅដល់ទីនោះគេប្រើខ្ញុំឲ្យធ្វើស្រែ គាស់គល់ឈើ ។ កាលពីជំនាន់ប៉ុលពត ស្រុកនេះជា ស្រុកកំពង់រោទ៍ដដែល តំបន់២៣ ភូមិភាគបូព៌ា ។

## កិច្ចសម្ភាសន៍ជាមួយ សេក សុខុន

ខ្ញុំឈ្មោះសេក សុខុនអាយុ៤៥ឆ្នាំ ។ មានស្រុកកំណើតនៅភូមិតាប៉ៅ ឃុំសំឡី ស្រុក កំពង់រោទ៍ ខេត្តស្វាយរៀង ។ ខ្ញុំសូមបញ្ជាក់ថា សមមិត្ត វ៉ន ដែលជាជនដៃដល់ក្នុងការសម្លាប់ មនុស្ស កាលពីជំនាន់ប៉ុលពតមានប្រពន្ធឈ្មោះអ៊ុក សាវី គ្មានកូន ។ សព្វថ្ងៃគាត់រស់នៅស្រុក អរិយក្សត្រ (ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្ដាល) ។ តាវ៉ននេះ មិនដែលមកលេងស្រុក កំណើតទេគឺមានតែប្រពន្ធប៉ុណ្ណោះដែលមក ប៉ុន្តែមកក្នុងលក្ខណៈមិនហ៊ានបញ្ចេញមុខទេ ព្រោះខ្លាច ប្រជាជន កងចលត័ក្នុងភូមិវៃស្លាប់ ព្រោះកាលនោះ(ប៉ុល ពត)គាត់ជាប្រធានកងចល័តឃុំ គ្រប់ គ្រងនារីក្នុងឃុំទាំងមូល ។ លក្ខណៈគ្រប់គ្រងគឺមានការកាចសាហាវបំផុត ។ សាវ៉នមានពណ៌សម្បុរ ខ្មៅស្រអែម កំពស់១,៦៨ម៉ែត្រ ស្គម អាយុជាង៣០ឆ្នាំកាលពីឆ្នាំ១៩៧៦ នៅពេលដែលគាត់ បានរៀប (អាពាហ៍ពិពាហ៍) ជាមួយសមមិត្តនារី សាវី ។ តាមខ្ញុំដឹងសមមិត្តវ៉ន មកកាន់គុក ឫស្សីសាញ់តាំងពីឆ្នាំ១៩៧៥មកម៉្លេះដោយទទួលខុសត្រូវខាងការងារសន្តិសុខរបស់ស្រុកតែម្ដង ។ សមមិត្តនារី សាវី ទទួលនាទីជំទប់របស់ឃុំតាំងពីឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧៧ទើបឈប់ពី ការងារ ។ សកម្មភាពការងាររបស់នារី សាវី គ្រាន់តែគ្រប់គ្រងការងារនៅក្នុងឃុំប៉ុណ្ណោះ ហើយ មានសកម្មភាពឃោសនាអប់រំខ្លាំងក្លាខាងឃោរឃៅព្រៃផ្សៃ គំរាមកំហែងការងារ ។ ចំណែក សមមិត្តសាវ៉នវិញ ឲ្យតែគាត់ចូលមកកាន់ភូមិឃុំណាហើយ គឺប្រាកដជាមានការចាប់ចងយកទៅ សម្លាប់ ។ សាវ៉នជាអ្នកស៊ើបការណ៍របស់ស្រុក ។ ចៅហ្វាយស្រុកឈ្មោះ សុផន ។ សាវ៉នជា (សេអ៊ីអា) សម្ងាត់របស់ស្រុកកំពង់រោទ៍ដែលបានទទួលបញ្ជាពីពេជ្រ សារឿន ។ ហើយពេជ្រ សារឿនក៏បានទទួលបញ្ជាពីចៅហ្វាយស្រុកឈ្មោះសុផន ឲ្យដាក់បញ្ជាបន្តមក សាវ៉ន ហើយសាវ៉ន ជាអ្នកដើរស៊ើបអង្កេតផ្ទាល់ ដូចជាស៊ើបអង្កេតរកបក្ខពួកខ្មែរស ។ ខ្មែរសជាមនុស្សដែលធ្វើ សកម្មភាពប្រឆាំងនឹងអង្គការកាលពីជំនាន់ប៉ុល ពត ។ កាលពីជំនាន់ខ្មែរក្រហម ខ្ញុំជឿថាពិតជាមាន សៀវភៅសំរាប់កត់ត្រាឈ្មោះអ្នកទោស ព្រោះពេលមកចាប់មិនដែលខុសឈ្មោះឡើយ ។ តាផន ខ្ញុំស្គាល់គាត់តាំងពីជំនាន់ប៉ុលពតម៉្លេះ ហើយកាលនោះគាត់មិនមែនជាសន្តិសុខគុកទេ ហើយក៏មិន មែនជាអ្នកចាត់ចែងអ្នកទោសដែរ គាត់គ្រាន់តែជាអ្នកគ្រប់គ្រងកងនារីបង្កបង្កើនផលមិនឲ្យរត់ ព្រោះបើកាលណាមានរត់គាត់(ផន) ត្រូវជាប់គុកជំនួស ។

## កិច្ចសម្ភាសន៍ជាមួយ ម៉ី សាម៉ុល

ខ្ញុំមានអាយុ៥៥ឆ្នាំ ។ មានស្រុកកំណើតនៅភូមិតាកឹង ឃុំព្រៃធំ ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ។ មុនជំនាន់ប៉ុល ពតខ្ញុំបានជម្លៀសពីមូលដ្ឋាននេះទៅនៅស្វាយរៀងក្នុងសម័យ លន់ ណុល ។ បន្ទាប់មកខ្ញុំបានបន្តការសិក្សានៅភ្នំពេញ គឺនៅសាលាទួលស្វាយព្រៃ[៣] រួចបន្ទាប់ពីប្រលងបាក់ឌុបជាប់ហើយគ្មានការងារធ្វើ ខ្ញុំក៏សុខចិត្តចូលធ្វើប៉ូលីសសាធារណរដ្ឋលោក អ៊ិន តាំ តាំងពីឆ្នាំ១៩៧៥ ។ មានប៉ុយរ៉ូធ្វើការនៅមុខបូឌិញ ។ បន្ទាប់មកលោកអ៊ិន តាំ លាតំណែងទៅរស់នៅឯបាត់ដំបងទៅ ខ្ញុំក៏ចូលធ្វើទ័ពនៅប៉េសេចំការដូង ។ រួចក៏បែកគ្នាទៀត ខ្ញុំក៏ធ្វើដំណើរមករកស្រុកកំណើតដោយឆ្លងកាត់តាមឃុំស្វាយតាយាន ។ ទៅដល់នោះ មានគេចោទថាខ្ញុំជាអ្នកកាន់ កាំភ្លើងធំដែលបណ្តាលឲ្យប្រជាជនរស់នៅក្នុងភូមិមិនបាន ហើយក៏គេបញ្ជូនទៅរៀនបន្តទៀត ។ ខាងមេឃុំជំនាន់ប៉ុលពតឈ្មោះ តាសាំ(ស្លាប់) និង វង(ស្លាប់) ។ គេបញ្ជូនខ្ញុំទៅដល់វត្តកញ្ជោរ បាន គេបោះចបបោះបង្គីរឲ្យ ទើបខ្ញុំដឹងថាខ្លួនត្រូវជាប់គុក ។ ដល់ពេលល្ងាចបានមកនៅវត្ត ពោធិថ្មី ឃុំស្វាយតាយានយើងនេះឲ្យលើកដីប្រឡាយ ។ ក្រោយមកទៀតគេបញ្ជូនខ្ញុំទៅចូលគុក ស្វាយតាយាន ព្រោះគេចាក់ចុចថាលួចពងមាន់ ។ ការងារលើកផ្លូវពីរនាក់៥ម៉ែត្រ ។ នៅដើមឆ្នាំ ១៩៧៦ ខ្ញុំត្រូវជាប់គុក ។ បន្ទាប់មកទៀតទៅប្រជុំនៅវត្តព្រៃធ្លកដោយអង្គការខ្វះកម្លាំងតាម
សហករណ៍ព្រៃតាញ៉ូយ ។ក្រោយមកទៀតម្តាយខ្ញុំដឹងថាខ្ញុំជាប់គុក រួចគាត់ក៏ស្នើតាពេជ្រ សាវឿនឲ្យបើកបញ្ជីមើលរួចក៏ឲ្យកងកម្លាំងទៅយកខ្ញុំមកដាក់នៅកន្លែងរបស់តាពេជ្រ សាវឿន ។ នៅកន្លែង នោះ ពេលថ្ងៃគេបញ្ជូនខ្ញុំមកវត្តសំប៉ែប ។ ពេលដេកគេឲ្យខ្ញុំទៅដេកនៅវត្តឬស្សីសាញ់ ។ ដល់ស្អាក់ នៅបានពីរយប់ក៏តាជួបជាអចិន្ត្រៃយ៍ តាពេជ្រ សាវឿនជិះកង់ទៅ រួចក៏ឲ្យពួកខ្ញុំតំរង់ជួរ បន្ទាប់មកគាត់(តាជួប) ក៏ហៅឈ្មោះខ្ញុំនិងឈ្មោះម្នាក់ទៀតមកថាត្រូវរួចខ្លួន ។ រួចព្រឹកឡើងក៏មក ធ្វើការនៅកន្លែងពេជ្រ សាវឿនដដែលគេឲ្យខ្ញុំមើលដំណាំដូង ខ្នុរ ។ រួចក៏ទៅប្រជុំនៅវត្តព្រះពន្លា គ្នាខ្ញុំ ១៣នាក់រួចខ្លួនទាំងអស់ ប៉ុន្តែគេឲ្យទៅនៅសហករណ៍សិន ។ បន្ទាប់គេបញ្ចូលខ្ញុំជាក្រុមសាមគ្គី ទៀតគេឲ្យកូនក្របីខ្ញុំមួយនឹមដើម្បីភ្ជួររាស់ ។ គ្រាន់តែក្របីឯងទៅហិតគូទក្របីគេៗកសាងមួយល្ងាច ទៅ ព្រោះចោទថាវាខុសសិលធម៌ ។

---

[៣] សាលាទួលស្វាយព្រៃ កាលពីជំនាន់ខ្មែរក្រហមកាន់អំណាច១៩៧៥-៧៩ គឺជាមន្ទីរសន្តិសុខស-២១(ទួលស្លែង)

គេកសាងថាមិត្តឯងឥឡូវនៅនិយាយសេរី និយាយរឿងពី សង្គម គ្រាន់និយាយថា «អើ!កាលពីយើងនៅរៀនហាក់ដូចជាសប្បាយ» ។ គ្រាន់តែប៉ុណ្ណោះ គេកត់ សម្គាល់ទុក រួចក៏យកយើងទៅកសាងទៅ ។

ខ្ញុំមិនបានចូលទៅក្នុងគុកបុស្សរីសាញ់ទេ ប៉ុន្តែខ្ញុំនៅសហករណ៍ លុះគេប្រើខ្ញុំឲ្យទៅយករទេះ នៅគុកបុស្សរីសាញ់ទៅដឹកជញ្ជូន ។ ពេលដឹកជញ្ជូននឹង បើជួបជាមួយកម្មាភិបាលគេ នោះប្រាកដជាគេឲ្យដោះគោនោះចេញ ហើយឲ្យទឹមខ្លួនឯងម្តង ។ អ្នកទោសធ្ងន់មិនបានឲ្យចេញពីគុកទេ ព្រោះជាប់ពាក់ពន្ធ័នឹងរឿងនយោបាយរបស់គេ ឯទោសស្រាលវិញគឺជាប់និន្នាការបន្តិចបន្តួច ។ ប្រធានគុកធំនោះឈ្មោះកែច ប៉ុន្តែក្នុងសៀវភៅរបស់ក្រុមស្រាវជ្រាវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដាក់ឈ្មោះថា ទុំ ខែង ។ មានមាឌស្តើង ។ អនុប្រធានឈ្មោះ ខុម ។ ឈ្មោះនេះសាហាវណាស់ ពេលបណ្តើរអ្នកទោសម្តងៗ វាបានដោតខ្សែអំបោះមួយសសៃតាមប្រឡោះឃ្លៀកអ្នកទោសទាំង ខ្សែៗ ប្រសិនបើដាច់ខ្សែអំបោះប្រាកដជាត្រូវវ៉ៃពេញគុកហើយ ។ ចំណែកឈ្មោះ ពេជ្រ សាវឿន ជាប្រធានមន្ទីរបុស្សរីសាញ់ ។ ឈ្មោះ សាវ៉ន ។ ឈ្មោះ ជួប ។ ឈ្មោះ បូ ។ ឈ្មោះ ផន នៅទួលសំប៉ប ជាមួយតា បូ ។ កាលណាយកប្រជាជនមកពីមូលដ្ឋានគឺចូលមន្ទីរសិន រួចទើប បញ្ជូនមកតាផន ។

តាផន មានតួនាទីទទួលខាងអ្នកទោសដែលគេបញ្ជូនមកទាំងធ្ងន់ទាំងស្រាល ។ រួចគាត់បែង ចែក កាលណាទោសធ្ងន់អ្នកឯងចូលគុក កាលណាផ្នែកនារីអ្នកឯងទោសស្រាល ឲ្យដើររកដើមចេកយកទៅចិញ្ចឹមជ្រូក ។ តាផន ធ្លាប់វ៉ៃមនុស្សឲ្យធ្វើការ ខ្ញុំឃើញផ្ទាល់ភ្នែកនូវការបញ្ចេញកំហឹង របស់គាត់គឺទាត់មួយជើង ពីរជើងទៅលើអ្នកធ្វើការ ។ តាផន ជាអ្នកសួរចម្លើយអ្នកទោស រួចគាត់មានបញ្ជីសំរាប់កត់ឈ្មោះអ្នកទោសផង ។ ចំណែក សាវ៉ន នៅជាប់ជាមួយ ពេជ្រ សាវឿន តាផនមកកាន់នៅមន្ទីរទួលសំប៉បតាំងពីដើមឆ្នាំ១៩៧៦ កាន់នាទីជាសន្តិសុខត្រួតអ្នកទោស ។ តាផនមានសៀវភៅសំរាប់បែងចែកអ្នកទោសធ្ងន់និងស្រាល ។ តាផន ក៏ជាអ្នកបណ្តើរអ្នកទោស ផ្នែកនារីពី៥០-៦០នាក់ទៅស្ទូងនៅតាមព្រំដែនដែរ ។ ចំណែកផ្នែកបុរសវិញច្រើនគ្រប់គ្រងដោយ មិត្ត កែច ។ គាត់(តាផន) ធ្លាប់បានបញ្ជារទៅប្រធានគុកមិត្ត កែច ថាឲ្យយកអ្នកទោសទៅសម្លាប់ ។ ខ្ញុំធ្លាប់ឃើញបញ្ជីសៀវភៅរបស់ តាផន ប៉ុន្តែឥឡូវមិនដឹងទៅណាទេ ។ សៀវភៅនោះ ដូចជា សៀវភៅរនោល ទំហឹបណ្តោយប្រហែលជាបីតឹក ទទឹងប្រហែលជាមួយតឹកកន្លះ កំរាស់ប្រហែល ជា២-៣ហ៊ុន ។ មានអ្នកទោសប្រហែលរាប់ពាន់នាក់ ។ សៀវភៅនេះមានក្របខាងក្រៅពណ៌ខ្មៅ ក្របរឹង ។

ពេលចុះទៅចាប់ប្រជាជនម្តងៗ ខ្ញុំបានឃើញ តាផន មានកាន់បញ្ជីនេះទៅជាមួយផង ។ ពេលចុះមកចាប់ប្រជាជន ក្នុងបញ្ជីរបស់គាត់មានឈ្មោះដែលត្រូវចាប់រួចទៅហើយ ព្រោះកាលនោះពួកគេបានបង្កប់កងឈ្លបតាមផ្ទះប្រជាជនដើម្បីស៊ើបការណ៍ពេលយប់ ។ លុះស៊ើបការណ៍ដឹងហើយកងឈ្លបនោះក៏មករាយការណ៍ជូន តាផន ហើយក៏តាផនកត់ឈ្មោះបញ្ចូលទៅក្នុងសៀវភៅ របស់គាត់ លុះបន្ទាប់មកក៏មកចាប់យកទៅដាក់គុកទៅ ។ ជួនកាលមានសហករណ៍គេមករាយ ការណ៍ប្រាប់ តាផន ពីនរណាម្នាក់ដែលគេស្អប់ ឲ្យតាផនមកចាប់គេទៅ ។ តាផន ជាអ្នកសរសេរ ផ្ទាល់ ។ តាផន មានស្រុកកំណើតនៅសំឡី(ភូមិសំឡី ឃុំសំឡី ស្រុកកំពង់រោទ៍) ។ មានប្រជាជនយើងច្រើនណាស់ដែលចង់សងសឹកទៅលើឈ្មោះ ផន ប៉ុន្តែមិនបានជួប ។ ឲ្យតែជួបគឺចិញ្ច្រាំដូច ប្រហុកអញ្ចឹង ។ ខ្ញុំឃើញថា តាផន មានសៀវភៅនេះតាំងពីដើមឆ្នាំ១៩៧៦ ហើយក្រោយមក មិនមានដូរសៀវភៅនេះទេ ។ ក្រោយពេលបែកខ្ញុំបានឃើញ តាផននោះរត់ទៅជាមួយពួកខ្ញុំ លុះ ទៅដល់បឹងវែ៉ ក៏បែកគ្នាត្រឹមបឹងវែ៉ទៅ ។ ហើយពេលដែលរត់ទៅនោះ ខ្ញុំបានឃើញ តាផន មាន កាន់កាតាបខ្មៅទៅជាមួយផង ។ ខ្ញុំជឿថា តាផន ពិតជាយកសៀវភៅនេះទៅជាប់ជាមួយខ្លួន ។ មូលហេតុដែល តាផន យកសៀវភៅនេះទៅជាមួយ ព្រោះគាត់យល់ថានៅមានអនាគតស្ថិត ស្ថេរទៅថ្ងៃមុខ ព្រោះពេលនោះគេមិនថាគេចាញ់ទេ គឺគេថយមួយរយៈ ។ ចំពោះពាក្យថា តាផន ត្រូវគេចាប់ឃុំយកទៅកាន់ស្វាយរៀង នេះជាពាក្យមិនពិតទេ ព្រោះតាផននេះឃោរឃៅណាស់ ។ តាផន ខ្ញុំឃើញគាត់នៅកាន់តំណែងនេះតាំងពីឆ្នាំ១៩៧៦រហូតដល់ចុងឆ្នាំ១៩៧៨ គាត់មិនបាន រត់ទៅនៅស្រុកកៀនស្វាយទេ ។ តាផន មានមាឌល្អិត សស្លើង ប្រមុះស្រួច ប្រការវែង ។ តាជួបស្លាប់នៅមុខអណ្តូងទឹកដោយសារតែគ្នាគេ ។ មូលហេតុស្លាប់ព្រោះតាជួបមានចិត្តស្រឡាញ់ ប្រជាជន ។ តាជួបស្លាប់ដោយសារគាត់លែងប្រជាជន និងទាហានច្រើនណាស់ ។ តាជួប ជា មនុស្សល្អ ព្រោះគាត់ជួយដោះលែងប្រជាជនយើង គាត់ចេះគិតគូរ ថ្លឹងថ្លែង ពិចារណាច្បាស់ លាស់ ។ អ្នកបញ្ជាឲ្យសម្លាប់ ជួប ប្រហែលជាពេជ្រ សារឿន ជាប្រធានមន្ទីរសន្តិសុខស្រុក តែម្តង ។ តាផន ជាមនុស្សមិនល្អទេ ។ តាជួបជាអនុប្រធានរបស់ ពេជ្រ សារឿន ។ ទាំងតាជួប តាពេជ្រ សារឿន តាផនសុទ្ធតែមានសៀវភៅទាំងអស់ ។ សៀវភៅអ្នកទោស ក្រៅពី តាផន មិនមានអ្នកណាមានទេ ។ តាផនមានតួនាទីខាងបែកចាយអ្នកទោសផង ខាងសេដ្ឋកិច្ចផង ខាងនារី ទៅធ្វើអង្ករ-បេះប្រាច់បបរបាយជ្រូកផង... ។ ចំពោះការបែងចែកអ្នកទោស តាផន ជាអ្នកបែង ចែកផ្ទាល់ ។

ទោសធ្ងន់ត្រូវប្រគល់ទៅឲ្យឈ្មោះ កែច ជាអ្នកគ្រប់គ្រង ។ ចំណែកទោសស្រាល គាត់ជាអ្នកគ្រប់គ្រងដោយផ្ទាល់ ។ កាលមានលិខិតពីពេជ្រ សារឿនមក តាផនជាអ្នកមើលរួចក៏ធ្វើការបែងចែកអ្នកទោសដែលបានបញ្ជូនមក ។ អ្នកទោសធ្ងន់ប្រគល់ទៅវត្តឫស្សីសាញ់ ៦អ្នកទោសស្រាលត្រូវនៅវត្តទួលសំប៉ែបនេះ អ្នកទោសណាក៏ដោយឲ្យតែចូលដល់ដៃតាផនហើយគឺគ្មានអ្នកណាមានជីវិតរស់នៅឡើយ ។ គាត់(តាផន) ជាអ្នកសម្លាប់មនុស្សដោយសន្តិវិធី ។ តាផនមានតួនាទីគ្រាន់តែជាអ្នកបែងចែកអ្នកទោសតាមប្រភេទស្រាល និងធ្ងន់ ប៉ុន្តែមានការសួរចម្លើយ អ្នកទោសខ្លះដែរ ។ ក្នុងការសួរចម្លើយគាត់គ្រាន់តែប្រាប់ប្រជាជនទាំងនោះថា"បើមានរឿងអីសូមឆ្លើយតាមត្រង់មកក្រែងលោខ្ញុំដាក់ទោសស្រាលឆាប់បានលែងទៅវិញ" តាមពិតគ្មានរឿងលែងទេក្រោយពេលបែកហើយ មានជីវិតរស់រានមកនេះ ខ្ញុំគ្មានគំនិតគំគួនជាមួយពួកនោះទេ មានតែការ សាមគ្គីគ្នា ។ ពួកវាសម្លាប់អស់ប៉ុន្មានលាននាក់ទៅហើយ បើយើងមានគំនិតចង់សងសឹង គំគួន ទៀតនោះគឺគ្មានសល់ទេ ។ ប៉ុន្តែអ្នកដែលមានខ្លួននោះមិនសូវហ៊ានមកអើតស្រុកទេ ។ ខ្ញុំចង់ឲ្យមានតុលាការមួយដើម្បីកាត់ទោសខ្មែរក្រហមមួយចំនួននេះ ដើម្បីកុំឲ្យមានសល់តទៅទៀត ។ ហើយក្រោយពីកាត់ទោសហើយមកគឺប្រាកដជាគ្មានការវិលត្រឡប់មកជាលើកទីពីរទៀតទេ ។ ប្រសិនបើមិនទាន់មានការកាត់ទោសខ្មែរក្រហមទេ ខ្ញុំនៅតែជឿពិតជាមានខ្មែរក្រហមបង្កប់ខ្លួន ។ នៅពេលមានតុលាការមួយ ខ្ញុំចង់មានសំណូមពរមួយគឺចង់ឲ្យខាងតុលារអន្តរជាតិចុះមកផ្ទាល់ ដោយរួមសហការជាមួយតុលារការជាតិ ដើម្បីស្វែងរកចាប់ជនឧក្រិដ្ឋមកកាត់ទោសឆាប់ៗ ។ ឈ្មោះ កែច ដែលជាអនុប្រធានគុកឫស្សីសាញ់នោះ បច្ចុប្បន្នខ្ញុំឮថារស់នៅស្អាង-កោះធំ (ស្រុកស្អាង-ស្រុកកោះធំ ខេត្តកណ្តាល) ។

ចំពោះបញ្ហាបញ្ជីអ្នកទោសនេះ នៅមានមនុស្សពីរនាក់ទៀតដែលទាក់ទងគឺៈ

១) សមមិត្ត សារ៉ន សព្វថ្ងៃរស់នៅឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល នេះតាមសេចក្តីរាយការណ៍របស់ សេក សុខុន ។ គួរបញ្ជាក់ដែរថា សារ៉ន ជាអតីតសន្តិសុខនៅគុកឫស្សី សាញ់ ហើយក៏ជាមនុស្សជំនិតរបស់ សមមិត្តពេជ្រ សារឿនដែរ ។ សារ៉ន មានប្រពន្ធឈ្មោះ សារី ដែលអតីតជាប្រធានកងចល័តឃុំតាំងពីឆ្នាំ១៩៧០ដល់១៩៧៧ ។ អ្នកទាំងពីរនាក់នេះ តាមសំដីរបស់ប្រជាជនមួយចំនួនបានប្រាប់ថា ជាមនុស្សកាចសាហាវណាស់ ។

២) សមមិត្ត កែច សព្វថ្ងៃរស់នៅស្រុកស្អាង ខេត្តកណ្តាល ។ អតីតជាអនុប្រធានគុក បុស្សី ។ ឈ្មោះនេះក៏ជាអ្នកសម្លាប់មនុស្សយ៉ាងសាហាវដែរ ។

អ្នកទាំងពីរនេះ សុទ្ធតែជាមនុស្សដែលស្គាល់តាផនច្បាស់ ហើយក៏ជាអ្នកដឹងច្បាស់ដែរថា តើតាផនមានបានធ្វើអ្វីខ្លះកាលពីជំនាន់នោះ(ប៉ុលពត) ។ បញ្ជីអ្នកទោសមួយនឹងត្រូវបានរក ឃើញថា តើនរណាជាអ្នកកាន់ បន្ទាប់ពីបានជួបជាមួយសមមិត្តទាំងពីរខាងលើរួច ។

ស្រុករមាសហែក

១) មន្ទីរសន្តិសុខវាលស្វាយ លេខកូដទីតាំងភូមិសាស្ត្រ ២០០៤០៨

ស្រុករមាសហែក មានទីតាំងស្ថិតនៅប៉ែកខាងលិចទីរួមខេត្តស្វាយរៀងប្រហែល៤៣គីឡូម៉ែត្រតាមផ្លូវជាតិលេខ១០ ។ ឃុំជ្រៃធំជាគោលដៅនៃក្រុមយើងក្នុងការស្វែងរកទីតាំងឧក្រិដ្ឋកម្មថ្មីដែលបានកំណត់ទុកតាមរបាយការណ៍កាលពីឆ្នាំ១៩៨២របស់សាលាខេត្តស្វាយរៀង ។ ជីវភាពប្រជាជននៅភូមិស្រះ ឃុំជ្រៃធំភាគច្រើនបំផុតគឺប្រកបរបរចិញ្ចឹមជីវិតដោយសារការបង្កបង្កើនផលលើផ្ទៃដីបន្តិចបន្តួចស្ថិតនៅខាងក្រោយផ្ទះរៀងៗខ្លួន ។ ពេលក្រុមយើងទៅដល់ផ្ទះរបស់លោកមេឃុំជ្រៃធំនៅម៉ោង១១:២៣យើងមិនបានជួបគាត់ទេ ព្រោះគាត់មានការប្រជុំនៅឯសាលាស្រុក រមាសហែក ដែលមានចម្ងាយប្រហែលជិត១០គីឡូម៉ែត្រពីផ្ទះរបស់គាត់ ។ “មន្ទីរសន្តិសុខវាលស្វាយអ្នកណាក៏ដឹងដែរ” នេះជាសំដីរបស់មីងមោង អ៊ុតដែលបានប្រាប់យើងយ៉ាងក្បោះក្បាយក្នុងពេលសម្ភាសន៍ ។ ប្រជាជនភាគច្រើនដែលរស់នៅទីនោះសុទ្ធតែបានដឹងគ្រប់ៗគ្នាថា ទីតាំងមន្ទីរសន្តិសុខវាលស្វាយ ជាមន្ទីរសំរាប់ឃុំឃាំងអ្នកទោសគ្រប់ប្រភេទ ។ មន្ទីរនេះត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៧៥ ក្រោយថ្ងៃជ័យជំនះរបស់ខ្មែរក្រហម(១៧/មេសា) ។ ប្រជាជនដែលបានជម្លៀសចេញពីទីក្រុងភ្នំពេញ និងពីទីរួមខេត្តស្វាយរៀង(ក្រុងស្វាយរៀង) សុទ្ធតែត្រូវបាននាំយកមកដាក់នៅទីនេះ(វាលស្វាយ)ទាំងអស់ ។ ក្នុងពេលដែលយកប្រជាជនទាំងនោះមកដាក់ គឺមិនបានឲ្យអ្នកទាំងនោះដើរដោយសម្រួលទេ ។ មីងមោង អ៊ុតរស់នៅក្នុងភូមិស្រះ ឃុំជ្រៃធំ ស្រុករមាសហែក បាននិយាយថា គាត់បានឃើញពួកខ្មែរក្រហមបណ្តើរអ្នកទោសដែលភាគច្រើនយកមកពីភ្នំពេញ និងស្វាយរៀងកាត់តាមផ្លូវនេះ(ផ្លូវជាតិលេខ១០)ទាំងខ្សែៗនៅឆ្នាំ១៩៧៥ បណ្តើរយកទៅកាន់មន្ទីរសន្តិសុខវាលស្វាយ ។ ចំណែកមីងចាន់ ដួ អាយុ៣៨ឆ្នាំ រស់នៅភូមិស្រះ ឃុំជ្រៃធំ ស្រុក រមាសហែក

ក៏បានប្រាប់ថាគាត់បានសង្កេតឃើញមានអ្នកដែលបណ្តើរអ្នកទោសនោះមានកាន់ កាំភ្លើងមុខក្រោយ ដើម្បីការពារអ្នកទោសមិនឲ្យលួចរត់ ។ ប្រជាជនជម្លៀសទាំងនោះមិនត្រូវបាន រួចខ្លួនពីសេចក្តីស្លាប់ឡើយ បន្ទាប់ពីបានចូលមកដល់មន្ទីរសន្តិសុខវាលស្វាយហើយនោះ ។ នៅពាក់ កណ្តាលឆ្នាំ១៩៧៥ ពួកខ្មែរក្រហមបានកំទេចចោលទាំងអស់នូវប្រភេទប្រជាជនថ្មីដែលខ្លួនបាន ចាប់មក ។ ក្រោយការសម្លាប់មន្ទីរនេះមិនស្ថិតនៅភាពទំនេរទេគឺមានបញ្ជូនចូលបន្ថែមនូវអ្នកទោស ជាច្រើនរយនាក់ទៀតដែលសុទ្ធសឹងតែជាប្រជាជនមូលដ្ឋាន ។ ចាប់ពីឆ្នាំ១៩៧៦រហូតមកដល់ ១៩៧៨ មន្ទីរនេះបានទទួលឲ្យចូលនូវគ្រប់ប្រភេទប្រជាជនទាំងអស់ដូចជា ប្រជាជនដែលមាន ស្បែកស១ខ្វះ អ្នកជាប់ខ្សែស្រឡាយជាមួយវៀតណាមខ្វះ ទាហានខ្មែរក្រហមដែលពួកខ្មែរ ក្រហមយល់ថាជាទាហានបក្សពួកខាងសោភឹមខ្វះ និងយកអ្នកទោសខ្វះពីវត្តស្វាយទន្ទឹមមកដាក់នៅ ទីនេះ(វាលស្វាយ) ដែរ ព្រោះពេលនោះនៅវត្តស្វាយទន្ទឹម[៤] ពេញហៀរដោយអ្នកទោសដែលត្រូវ យកទៅសម្លាប់ឲ្យនៅលាយចំរុះគ្នា ។ លោកពូម្នាក់ឈ្មោះភឹម សាក់បានរៀបរាប់ប្រាប់យើងថា គាត់ជាទាហានខ្មែរក្រហមម្នាក់ខាងបក្សពួកសោភឹមស្ថិតនៅក្នុងកងពលលេខ៣ ដែលត្រូវបានចាប់ខ្លួន មកដាក់នៅមន្ទីរសន្តិសុខវាលស្វាយនៅដើមឆ្នាំ១៩៧៨ គឺនៅពេលដែលទាហានខាងសោភឹម ត្រូវ បែកខ្ញែកមកដោយសារការវាយប្រហារពីពួកខ្មែរក្រហមម្ខាងទៀត ។ លោកពូបានរៀបរាប់ថា អ្នកគ្រប់គ្រងនៅមន្ទីរសន្តិសុខវាលស្វាយនេះឈ្មោះ តាភ័ណ ជាប្រធាន និង តាសំអេន ជាអនុ ប្រធាន ។ ទាំងពីរនាក់នេះមិនមែនជាអ្នកសម្លាប់មនុស្សទេ ។ អ្នកទោសទាំងអស់ត្រូវនាំយកទៅ សម្លាប់នៅទួលមួយដោយកូនចៅមួយចំនួនរបស់តាភ័ណ និងតាសំអេន ។ អ្នកទោសទាំងអស់ភ័យ យ៉ាងខ្លាំងពេលដែលខ្លួនត្រូវបានពួកខ្មែរក្រហមដាក់បាយឲ្យហូបនៅផ្ទាល់ដី ព្រោះសកម្មភាពនេះជា ប្រការមួយដែលបញ្ជាក់យ៉ាងច្បាស់ថា ពិតជាមានការសម្លាប់មនុស្សក្រោយពេលបរិភោគបាយ រួច ។ នេះជាទំលាប់របស់ពួកខ្មែរក្រហមពេលដែលយកមនុស្សទៅសម្លាប់ម្តង១ ។ អ្នកទោសភាគ ច្រើនមិនត្រូវបានរួចខ្លួនមកវិញឡើយនៅពេលដែលបានទៅជាប់នៅមន្ទីរនេះហើយ ប៉ុន្តែលោកពូ ភឹម សាក់ បែរជាមានសំណាងបានរួចខ្លួនមកវិញ ហើយមានជីវិតរស់រហូតដល់សព្វថ្ងៃ ។ មូល ហេតុនេះលោកពូភឹម សាក់បានប្រាប់យើងថាអ្នកទោសដែលជាប់តាំងពីឆ្នាំ១៩៧៥ មកដល់ចុងឆ្នាំ ១៩៧៧

---

[៤] ទីតាំងវត្តស្វាយទន្ទឹមនោះ ក្រុមយើងបានចុះទៅស្រាវជ្រាវម្តងរួចហើយកាលពីឆ្នាំ១៩៩៥ ។

សុទ្ធតែត្រូវស្លាប់ទាំងអស់ ។ ចំណែកអ្នកដែលជាប់ក្រោយពីនោះដែលមានចំនួនប្រហែលជាង១០០នាក់ត្រូវបានដោះលែងឲ្យរួចខ្លួនខ្លះ និងបញ្ជូនទៅកាន់អ្នកលឿងខ្លះ ព្រោះជិតដល់ថ្ងៃរំដោះឆ្នាំ១៩៧៩ ។

២) ទីតាំងពិឃាតនៅទួលព្រៃស្វឹក លេខកូតភូមិសាស្ត្រ ២០០៤០៧

ទួលមួយកណ្តាលវាលស្រែ ក្លាយជាទួលសម្រាប់សម្លាប់មនុស្សតាំងពីពាក់កណ្តាលឆ្នាំ១៩៧៥រហូតមកដល់ដើមឆ្នាំ១៩៧៩ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ ទីទួលនោះមានឈ្មោះថាទួលព្រៃស្វឹកដែលស្ថិតនៅក្នុងភូមិស្រះ ឃុំជ្រៃធំ ស្រុករមាសហែក ។ អ្នកទោសស្ទើរតែទាំងអស់ដែលបានបញ្ជូនពីមន្ទីរសន្តិសុខវាលស្វាយមកសម្លាប់ គឺគ្មានកន្លែងណាក្រៅពីទីតាំងពិឃាតទួលព្រៃស្វឹកនេះឡើយ ។ មីងមោង អ៊ុតបាននិយាយថាមានរណ្តៅច្រើន ហើយក្នុងមួយរណ្តៅៗមានសាកសពលើសពី១០នាក់ ។ កែន សៀក អាយុ៣៥ឆ្នាំ រស់នៅភូមិស្រះ ឃុំជ្រៃធំ ស្រុករមាសហែកបានប្រាប់ថាមានប្រហែលពី៤០០ទៅ៥០០រណ្តៅ ហើយក្នុងមួយរណ្តៅៗ មានទំហំចាប់ពី២ម៉ែត្រឡើងទៅនិងជំរៅ១ម៉ែត្រ ។ មានសាកសពរាប់ពាន់នាក់ បូករួមទាំងសាកសពដែលបានស្លាប់នៅក្នុងអណ្តូងទឹកមួយនៅក្បែរមន្ទីរសន្តិសុខវាលស្វាយផង ។

ក្រោយឆ្នាំ១៩៧៩ រណ្តៅទាំងនោះត្រូវបានគាស់ដោយកងទ័ពវៀតណាមរួមជាមួយប្រជាជនកម្ពុជាដើម្បីយកអដ្ឋិធាតុទាំងនោះទៅដាក់តំកល់នៅទីតាំងវត្តជ្រៃធំក្នុងភូមិដងក្តា ។ ក្នុងការគាស់រណ្តៅទាំងនោះមានប្រជាជនក្នុងភូមិច្រើនណាស់បានដឹងនិងបានឃើញផ្ទាល់ភ្នែក ។ ជាក់ស្តែង មីងសុខ វឿន មោង អ៊ុត ចាន់ ជូ និងអ្នកផ្សេងទៀតបាននិយាយថាមានលលាដ៍ក្បាលច្រើនណាស់រហូតដល់ជាង៣រទេះគោឯណោះ ។ លលាដ៍ក្បាលទាំងនេះ ត្រូវបានគាស់ឡើងនៅឆ្នាំ១៩៨០ដោយកងកម្លាំងរបស់កងទ័ពវៀតណាមរួមសហការជាមួយប្រជាជនកម្ពុជាដែលភាគច្រើនមកពីទីក្រុងភ្នំពេញ ។ អ្នកស្រុកនិយាយថា អ្នកដែលមកជីករណ្តៅនេះមានសំលៀកបំពាក់ស្អាតបាតទំនងជាអ្នកធ្វើការធំនៅភ្នំពេញ ។ អដ្ឋិធាតុដែលបានគាស់នោះគឺបានប្រហែលមួយភាគប៉ុណ្ណោះនៃឆ្អឹងដែលនៅក្នុងដីសព្វថ្ងៃនេះ ។ ហើយភាគច្រើនបំផុតនៃឆ្អឹងដែលបានគាស់នោះ គឺលលាដ៍ ក្បាល ។ ក្រោយការគាស់ឆ្អឹងទាំងនោះត្រូវបានយកមកតំកល់នៅវត្តជ្រៃធំ ដែលស្ថិតនៅក្នុងភូមិ ដងក្តារ ឃុំជ្រៃធំ បន្ទាប់ពីមានការថតរូបជាឯកសារដោយ...................... និងដុះលាងរួចមក ។ ដោយការការពារមិនដិតដល់

អដ្ឋិធាតុទាំងនោះត្រូវបានដឹកជញ្ជូនយកទៅកាន់វត្តតាហង់ចាស់ ដែល បច្ចុប្បន្នហៅថាវត្តកំពង់ត្រាច[៥] ព្រោះទីនោះមានសន្តិសុខជាង ។ ចំនួនលលាដ៍ក្បាលដែលបានគាស់ នោះ ចាន់ ផូបានធ្វើការសន្និដ្ឋានថាមានពី២០០ទៅ៣០០ក្បាល ។

ខាងក្រោមនេះជាសំដីផ្ទាល់មាត់របស់ប្រជាជននៅភូមិស្រះ ឃុំជ្រៃធំ ដែលបានសម្រាយបំភ្លឺពីមន្ទីរសន្តិសុខវាលស្វាយ និងកន្លែងពិឃាតទួលព្រៃស្វឹក ។

## កិច្ចសម្ភាសន៍ជាមួយអ៊ំស្រី មោង អ៊ុត

ខ្ញុំមានអាយុ៥៨ឆ្នាំ ។ ខ្ញុំមានស្រុកកំណើតនៅហ្វឹងតែម្តង (ភូមិស្រះ ឃុំជ្រៃធំ ស្រុក រមាសហែក ខេត្តស្វាយរៀង) ។ ខ្ញុំបានឃើញកន្លែងដែលគេ(ខ្មែរក្រហម) សម្លាប់នៅក្បែរស្រែខ្ញុំ ដែរ ។ ក្នុងមួយរណ្តៅមានប្រហែល១០នាក់ ។ ជនរងគ្រោះច្រើនយកមកពីស្វាយរៀង ពីភ្នំពេញ កាលពីឆ្នាំ១៩៧៥ ។ ខ្ញុំឃើញជនរងគ្រោះត្រូវបានបណ្តើរមកតាមថ្នល់នេះ(ថ្នល់ជាតិលេខ១០)
ដោយចងជាខ្សែៗយកទៅដាក់គុកនៅវាលស្វាយក្នុងភូមិស្រះ ឃុំជ្រៃធំ ស្រុករមាសហែក ខេត្តស្វាយរៀង ។នៅឆ្នាំ១៩៧៩ មានកងទ័ពវៀតណាមរួមជាមួយប្រជាជនយើងបាននាំគ្នាគាស់រណ្តៅសាកសពទាំងនោះ ។ គាស់នាពេលនោះបានតែលលាដ៍ក្បាលទេ ដែលមានចំនួនរាប់រយក្បាល ។ ក្រោយពីហាលលលាដ៍ក្បាលទាំងនោះស្ងួតទៅ ក៏យករទេះគោមកដឹកយកទៅដាក់នៅវត្តជ្រៃធំ ។ កាលពីគាស់នោះនៅធំក្លិនស្អុយនៅឡើយ ។ បច្ចុប្បន្នឆ្អឹងទាំងនោះដែលបានយកទៅដាក់នៅវត្តជ្រៃ (វត្តជ្រៃធំ) នោះមិននៅទេ គឺយកទៅដាក់នៅវត្តតាហង់ ហៅវត្តកំពង់ត្រាចរហូតដល់បច្ចុប្បន្ននេះ ព្រោះកាលនោះមានគោមកស៊ីឆ្អឹងនៅវត្តជ្រៃ ។

## កិច្ចសម្ភាសន៍ជាមួយមីង ចាន់ ផូ

ខ្ញុំមានអាយុ៣៨ឆ្នាំ ខ្ញុំបានឃើញផ្ទាល់ផ្នែកនូវការបណ្តើរមនុស្សទាំងខ្សែៗ ដែលជម្លៀស មកពីទីក្រុង អ្នកធ្វើការ.....។ ពេលបណ្តើរ អ្នកបណ្តើរនោះមានកាន់កាំភ្លើងមុខក្រោយដើម្បីការ ពារកុំឲ្យអ្នកទោសរត់ ។ អ្នកទោសច្រើនជាប្រជាជនជម្លៀសពីកន្លែងឆ្ងាយៗ ខ្លះមានសក្តិ២ខ្លះ៣ ។

---

[៥] នៅក្នុងរបាយការណ៍ឆ្នាំ១៩៩៥របស់ក្រុមដែនទី វត្តនេះបានចុះស្រាវជ្រាវរួចហើយ ។

ចំណែកប្រជាជនមូលដ្ឋានច្រើនបញ្ជូនទៅកាន់ខេត្តឆ្ងាយៗ ដូចរូបខ្ញុំទៅនៅឯពោធិសាត់ឯណោះ ។ លលាដ៍ក្បាលដែលគាស់បាននោះមានច្រើនណាស់ ដឹកបីរទេះឯណោះ ។ លលាដ៍ក្បាលសរុបទាំងអស់ប្រហែលពី២០០-៣០០នាក់ ។ នៅច្រើនទៀតដែលគាស់មិនអស់ ។ ឆ្អឹងដែលគាស់រួចនោះត្រូវយកទៅទុកនៅក្នុងវត្តជ្រៃធំ ស្ថិតនៅភូមិដងក្តារ ឃុំជ្រៃធំ ។ មូលហេតុដែលបានឃើញរៀតណាមគាស់រណ្តៅសាកសពដោយសារពេលនោះគាត់ទៅសួងស្រែ ។ ខ្ញុំមិនដឹងថាមានរណ្តៅចំនួន ប៉ុន្មានទេ ។ ជនរងគ្រោះខ្លះដឹកយកមកពីវត្តស្វាយទន្ទឹម ព្រោះនៅទីនោះ(វត្តស្វាយទន្ទឹម)ដាក់មិន អស់ ។

## កិច្ចសម្ភាសន៍ជាមួយលោកពូភឹម សាក់

ខ្ញុំមានអាយុ៤២ឆ្នាំ ។ស្រុកកំណើតខ្ញុំនៅភូមិត្រគៀបក្តាម ឃុំត្រពាំងស្តៅ ស្រុករមាស ហែក ខេត្តស្វាយរៀង ។ ខ្ញុំជាទាហានធ្វើការនៅកងពលលេខ៣របស់ខ្មែរក្រហម ។ ខ្ញុំត្រូវរបួស ហើយទៅដេកពេទ្យនៅខេត្តព្រៃវែង ហើយបន្ទាប់មកក៏មានការវាយបក្សពួកខាង សោភឹម ក៏ច្របូក ច្របល់ ហើយខ្ញុំក៏ត្រឡប់មកផ្ទះ ។ មកដល់ផ្ទះបានមួយយប់ ស្រាប់តែគេ(ពួកខ្មែរក្រហម) ទៅចង ខ្ញុំមកដាក់នៅមន្ទីរសន្តិសុខនៅវាលស្វាយ ។ ពេលមកដល់មន្ទីរនេះ ខ្ញុំត្រូវគេដាក់ខ្នោះដៃ ជើង ។ ក៏មានការសួរចម្លើយខ្លះៗដែរ ប៉ុន្តែគ្មានវ៉ៃចំពោះខ្លួនខ្ញុំ តែវ៉ៃគេផ្សេងៗ ។ ក្រោយមកអ្នកវ៉ៃគេ នោះត្រូវពួកនិរតីចាប់ចងទៅលិច (អ្នកលឿង ភ្នំពេញ) ទៅ ។ ពេលយកទៅលិចនោះមានអ្នក ទោសទាំងអស់ចំនួន២៩នាក់រួមទាំងខ្ញុំផង ។ ពួកគេចេះតែបញ្ជូនទៅរហូតដល់ស្រុកមោង ខេត្ត បាត់ដំបង ។ អ្នកជាប់ទោសនៅវាលស្វាយ នេះមានចំនួនជាងមួយរយនាក់ ។ អ្នកទោសមួយចំនួន ត្រូវបានដោះលែងខ្លះ ។ មានយកទៅសម្លាប់ខ្លះនៅទួលមួយក្បែរគុកនេះ ។ គេដាក់បាយឲ្យស៊ីផ្ទាល់ នឹងដី រួចក៏យកទៅសម្លាប់ចោលទាំងអស់ចំនួន២៩នាក់ ។ អន្លង់ដែលខ្ញុំឃើញដឹកពីល្ងាច ស្រាប់តែ មិនឃើញព្រោះសាកសពណែនអស់ ។ អន្លង់នេះដឹកដោយពួកសន្តិសុខ ។បច្ចុប្បន្ននេះត្រូវបានគាស់ ហើយ ។ អន្លង់នោះឈ្មោះ**ត្រពាំងអញ្ចាញ** ។ បច្ចុប្បន្នគាស់អស់ហើយ ប៉ុន្តែមិនបានរើសយកឆ្អឹង អស់ទេ ។ អ្នកទោសទាំងអស់ច្រើនយកទៅ សម្លាប់នៅក្នុងព្រៃមួយឈ្មោះថា**ព្រៃស្វឹក** ។ ទាហាន ពួកខ្ញុំចំនួន២៨នាក់ត្រូវបញ្ជូនទៅកាន់អ្នកលឿង ក្នុងចំនោមអ្នកទោសជាងមួយរយនាក់ដែលភាគ ច្រើនជាទាហានរបស់បក្សពួកសោភឹម ។ ពេលទៅដល់លិច(អ្នកលឿង) ខ្ញុំលួចរត់ ហើយ៧ថ្ងៃ ក្រោយទើបទៅដល់ស្រុកមោង ខេត្តបាត់ដំបងទើបរួចខ្លួន ។ អ្នកទាំង២៨នាក់នោះ មានខ្លះនៅរស់

នៅឡើយដូចជាឈ្មោះ ភាជ នៅភូមិអំពិល ឃុំអំពិល តានន់ នៅភូមិព្រៃតាមូរ ឃុំសំបួរ និងឈ្មោះ អាណើប នៅភូមិអណ្តូងខ្ពត់ ឃុំសំបួរ ។ ពួកខ្ញុំរត់មុន ថ្ងៃរំដោះ ។ មេគ្រប់គ្រងនៅ វាលស្វាយឈ្មោះ តាភ័ណ ប្រធានសន្តិសុខ ។ សំអេន ជាអនុប្រធានសន្តិសុខវាលស្វាយ ។ កូនចៅរបស់តា ភ័ណ និង សំអេន ជាអ្នកវាយសម្លាប់ ។ ប្រជាជនដែលបានជម្លៀសពីទីក្រុង ភ្នំពេញមកនោះគឺវៃសម្លាប់មុន(១៩៧៥) ។ បន្ទាប់មកវៃអ្នកមូលដ្ឋាន ហើយចុងក្រោយគឺវៃ ទាហានបូព៌ាចុងក្រោយគេ ។ ប្រជាជនចាស់ដែលខុសសីលធម៌ក៏យកមកសម្លាប់នៅហ្នឹងដែរ ។ ក៏មានការសម្លាប់ដែលទាក់ទងនឹងជនជាតិដែរគឺជនជាតិវៀតណាម ។ ប្រជាជនដែលមានពណ៌សម្បុរស ៗក៏យកមកសម្លាប់នៅទីនេះដែរ ។ ទីតាំងនេះមានសម្លាប់តាំងពីឆ្នាំ១៩៧៥មករហូតដល់ដើម ឆ្នាំ១៩៧៩ ។ ខ្ញុំជាប់គុកនេះ ពេលយប់គេដាក់ខ្នោះខ្ញុំ ពេលថ្ងៃលែងខ្នោះឲ្យទៅធ្វើការដូចជាបោច ស្មៅសន្ទូង ស្ទូងដកធម្មតា ដល់ពេលហូបបាយរួចដាក់ខ្នោះ ។ ពេលដេកគ្មានកន្ទេលទេ ។ ពេលសួរចម្លើយមានវៃខ្លះ ។ ពេលសួរចម្លើយគឺសួរតែពីប្រវត្តិបងប្អូនធ្វើអីខ្លះ មានគ្នាប៉ុន្មាន នាក់? ។ ចំណែកម្ហូបបាយវិញ គេឲ្យស៊ីនៅលើដី ដោយមានដាក់ទ្រាប់ស្លឹកចេកតូចៗឲ្យស៊ី ។ ម្ហូបវិញគឺស្ល‌ត្រគៀតបង់អំបិលគ្មានត្រីសាច់ទេ ។ ខ្ញុំបានឃើញគេបណ្តើរយកទៅសម្លាប់ជារៀង រាល់ថ្ងៃ ។ គុកនេះជាគុកវាលស្វាយ ។ ចំណែកកន្លែងសម្លាប់វិញស្ថិតនៅព្រៃស្លឹក ។ ខ្ញុំមានកំហឹង ឈឺចាប់ចំពោះពួកខ្មែរក្រហម ។ កាលពីមុននៅពេលដែលខ្ញុំចូលធ្វើការបានប្រហែលមួយខែ ក្រោយបែក ខ្ញុំមានកំហឹងចង់សងសឹកទៅលើពូខ្ញុំម្នាក់ដែលជាសន្តិសុខនៅវាលស្វាយ តែត្រូវគាត់ (ពូ) រត់បាត់ ។ មូលហេតុសងសឹកព្រោះកាលនោះ ខ្ញុំសុំគាត់ទៅបត់ជើងតូចនៅពេលដែលខ្ញុំរែក កណ្តាប់ស្រូវ ស្រាប់តែគាត់តំរ៉ង់កាំភ្លើងមកខ្ញុំ ហើយស្រែកថា «អ្ហែង! ទៅៗ» ។ សូម្បីតែសម្ល ដែលនៅសល់ក៏មិនឲ្យខ្ញុំស៊ីដែរ គឺសុខចិត្តជះចោលទៅដី ។ ខ្ញុំគាំទ្រអោយមានតុលាការដើម្បីកាត់ ទោសខ្មែរក្រហម ព្រោះពួកវាធ្វើបាបគេច្រើនណាស់ ។ ខ្ញុំជាទ័ពខ្មែរក្រហមពីឆ្នាំ១៩៧៥ - ៧៧ ហើយក្រោយមកក៏ជាប់នៅទីនេះតាំងពីចុងឆ្នាំ១៩៧៨មក ។ ខ្ញុំជឿថា តុលាការដែលបានបង្កើត ដើម្បីកាត់ទោសខ្មែរក្រហមនេះពិតជាត្រឹមត្រូវ ។ ឲ្យតែបានកាត់ទោសអាមេៗទៅ អាកូនចៅតូច តាចហ្នឹងយើងគួរសំរាលទៅ ព្រោះជាមនុស្សនៅក្នុងភូមិ ។ ក្រោយពេលកាត់ទោស ខ្ញុំជឿថាអត់ មានខ្មែរក្រហមជាលើកទី២ ទៀតទេ ។

## កិច្ចសម្ភាសន៍ជាមួយ សុខ វ៉ុន

ខ្ញុំមានអាយុ២៦ឆ្នាំ ។ មានស្រុកកំណើតនៅភូមិស្រះ ឃុំជ្រៃធំ ស្រុករមាសហែក ។ ខ្ញុំបានឃើញគេគាស់ ប៉ុន្តែការវៃប្រជាជនមិនបានឃើញទេ ។ មានរណ្តៅច្រើនណាស់ គ្រាន់តែខាងក្រោយផ្ទះខ្ញុំមានដូចរន្ធបាយខំអញ្ចឹង ។ ក្បាលខ្មោចដែលគាស់បានមានច្រើនណាស់ ទាំងបាវៗខាង ជើងផ្ទះខ្ញុំតំរៀបជាជួរៗ រួចថត ហើយដឹកយកទៅវត្តជ្រៃ ហើយក្រោយមកដឹកទៅវត្តតាហង់ ។ អ្នកគាស់ច្រើនមកពីភ្នំពេញ ហើយប្រហែលជាអ្នកធ្វើការធំៗហើយ ។

## កិច្ចសម្ភាសន៍ជាមួយមីង កែន សៀត

អាយុ៣៩ឆ្នាំ មានស្រុកកំណើតនៅភូមិស្រះ ឃុំជ្រៃធំ ស្រុករមាសហែក ។ ខ្ញុំបានដឹងដូច ឈ្មោះជា សារ៉ាន អាយុ៤២ឆ្នាំ និង ឈ្មោះ ម៉ៅ យាន អាយុ៤០ឆ្នាំ មានស្រុកកំណើត នៅហ្នឹងដែរ ថាបានឃើញមានការគាស់រណ្តៅខ្មោចមែនកាលពីឆ្នាំ១៩៨០ ។ មានរណ្តៅច្រើន ណាស់ ខ្លះមានទំហំបណ្តោយ២ម៉ែត្រ បណ្តោយប្រហែល៣ម៉ែត្រ ជំរៅ១ម៉ែត្រ ។មួយរណ្តៅៗ មានប្រហែលពី១៥-២០នាក់ ។ មានប្រហែលពី៤០០-៥០០រណ្តៅទាំងតូចទាំងធំ ។ សាកសព ប្រហែលរាប់ពាន់នាក់ ។ មានវៃទំលាក់នៅក្នុងអណ្តូងទឹកផង ។ អណ្តូងនេះមានទំហំប្រហែល ១០ ម៉ែត្រជាង ។ សាកសពពេញអណ្តូង ប៉ុន្តែមិនបានគាស់ទេ ។

## សេចក្តីសន្និដ្ឋាន

គោលបំណងពីរ ក្នុងដំណើរទៅកាន់ខេត្តស្វាយរៀងគឺ ផ្តោតសំខាន់ទៅលើបញ្ជីអ្នកទោសដែលត្រូវបានថែរក្សាទុកដោយអតីតសន្តិសុខខ្មែរក្រហមម្នាក់ឈ្មោះ**ផន**(មាស ផន) និងស្វែងរកទីតាំងសម្លាប់មនុស្សថ្មីដែលមាននៅក្នុងបរិវេណស្រុករមាសហែក ជាពិសេសភូមិស្រះ ឃុំជ្រៃធំ ។ ឯលទ្ធផលដែលទទួលបានគឺៈ

១) សៀវភៅដែលក្រុមយើងស្វែងរកនោះ ទោះជាមិនបានឃើញនិងមិនបានទទួលដោយ ផ្ទាល់ក៏ពិតមែន ប៉ុន្តែយ៉ាងហោចណាស់ក៏យើងបានទទួលពត៌មានពី**តាផន**ដែលជាអ្នកកាន់សៀវភៅ នោះកាលពីជំនាន់ប៉ុលពត និងពីបណ្តាសាក្សីផ្សេងទៀតដែលបានឆ្លងកាត់ផ្ទាល់នៅក្នុង របបខ្មែរក្រហមព្រមទាំងធ្លាប់បានទទួលរងនូវការធ្វើបាប ផ្ទាល់ពី **តាផន** ផង ។ តាផន បាននិយាយថា

គាត់ធ្លាប់ធ្វើជាទាហានខ្មែរក្រហមនៅឆ្នាំ១៩៧៥ ។ នៅឆ្នាំ១៩៧៦ គាត់បានលាឈប់ពីទាហាន មកបំរើការជាអ្នកមើលការខុសត្រូវលើក្រុមនារី ១២ នាក់នៅវត្តទួលសំប៉ប ស្ថិតនៅក្នុងឃុំព្រៃធំ ស្រុកកំពង់រោទ៍ ។ កិច្ចការរបស់គាត់គឺ ការពារកងនារី ទាំងនោះមិនឲ្យលួចរត់ ព្រមទាំងដឹកនាំក្រុម នារីបង្កបង្កើនផលនិងរកប្រាប់ឲ្យជ្រូកស៊ី ។ លុះដល់ឆ្នាំ ១៩៧៧ ពេលដែលពួកនិរតីចូលមក**តាជន** ក៏ត្រូវផ្លាស់ប្តូរទីលំនៅ និងមុខនាទីទៅរស់នៅក្នុងទឹកដីឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ក្នុងនាមជាអ្នកជម្លៀស ។ ការងាររបស់តាជននៅឃុំសំរោងធំ គឺធ្វើស្រែ និងគាស់គល់ឈើ ។ ទោះជាយ៉ាងនេះក្តីសំដីរបស់គាត់ទាំងប៉ុន្មានខាងលើ ផ្ទុយគ្នាទាំងស្រុងរវាងលោកចាន់ សុគាត ជាអនុប្រធានមន្ទីរវប្បធម៌ស្រុក ក៏ដូចជាលោកមេឃុំព្រះពន្លាដែលបាននិយាយថា តាជន ជាមនុស្សម្នាក់ដែលមានសៀវភៅអ្នកទោសជាប់នឹងខ្លួន ព្រោះគាត់ជាអ្នកបែងចែកអ្នកទោសតាមប្រភេទធ្ងន់ និង ស្រាល ។ ម៉ី សាម៉ុលបាននិយាយថា តាជន ជាមនុស្សឃោរឃៅពិតប្រាកដ ហើយក៏ពិតជាមានបញ្ជីអ្នកទោសនៅជាប់នឹងខ្លួនដែរ ព្រោះក្រោយពេលបែក គាត់(សាម៉ុល)បានឃើញ តាជន មានកាន់កាបូបធំមួយ ហើយខាងក្នុងការបូបនេះមានសុទ្ធតែឯកសារទាំងអស់ ព្រោះកាល នោះតាជនយល់ថា ពួកគេ(ខ្មែរក្រហម) នៅមានអនាគតភ្លឺស្វាងដដែល ។ តាជនមានតួនាទីពីរគឺ គ្រប់គ្រងអ្នកទោសប្រភេទស្រាល(នារី) និងអ្នកបែងចែកអ្នកទោស ។ ភាពឃោរឃៅរបស់គាត់ ត្រូវបានប្រជាជនរស់នៅឃុំព្រៃធំស្ទើរតែទាំងអស់នៅចាំជាប់ជានិច្ច ហើយមានគំនុំគួនរហូតដល់ សព្វថ្ងៃ ។

២) ស្វែងរកទីតាំងពិឃាតថ្មីនៅភូមិស្រះ ឃុំជ្រៃធំ ស្រុករមាសហែក ។ នៅទីនោះយើង បានជួបជាមួយជនរងគ្រោះម្នាក់ដែលធ្លាប់ជាប់គុកនៅវាលស្វាយ ។ មានទីតាំងពីរនៅក្នុងភូមិតែ មួយគឺ ទីតាំងមន្ទីរសន្តិសុខវាលស្វាយ និង ទីតាំងសម្លាប់ព្រៃស្ទឹក ។ អ្នកទោសគ្រប់ប្រភេទត្រូវ បានបញ្ជូនចូលមកក្នុងគុកនេះ ។ ដំណើរការនៃមន្ទីរនេះ មានចាប់តាំងពីឆ្នាំ១៩៧៥មករហូតដល់ឆ្នាំ ១៩៧៨ ។ មន្ទីរនេះដំបូងដាក់អ្នកទោសប្រភេទប្រជាជនថ្មីដែលបានជម្លៀសពីភ្នំពេញ និងទីរួម ខេត្តស្វាយរៀង ។ បន្ទាប់មកយកអ្នកទោសជាអ្នកមូលដ្ឋានមកដាក់បន្ត ក្រោយពេលយកអ្នកទោស ដែលជម្លៀសទៅសម្លាប់អស់ ។ ចុងក្រោយបំផុតគុកនេះ ដាក់តែទាហានខ្មែរក្រហមដែលត្រូវបាន ចោទថាជាទាហានខាង សោភឹម ។ អ្នកទោសចុងក្រោយនេះ មានសំណាងខ្លះអាចរួចខ្លួន ព្រោះជិត ដល់ថ្ងៃរំដោះ ។

ឯទីតាំងសម្លាប់វិញ ស្ថិតនៅចំងាយប្រហែល៨០០ម៉ែត្រទៅទិសខាងត្បូងនៃមន្ទីរសន្តិសុខ វាលស្វាយ ។ ស្ថិតនៅចំកណ្តាលវាលស្រែដែលលិចទឹកជុំវិញនាពេលបច្ចុប្បន្ននេះ ។ ទួលព្រៃស្ទឹក

នេះបានក្លាយជាកន្លែងកប់សាកសពតាំងពីឆ្នាំ១៩៧៥មក ក្រោមការសម្លាប់យ៉ាងព្រៃផ្សៃរបស់ ខ្មែរក្រហម ។ ទួលព្រៃស្វឹកនេះមានរណ្តៅសរុបទាំងអស់ចំនួនពី៤០០ទៅ៥០០រណ្តៅ ហើយក្នុងមួយរណ្តៅៗមានសាកសពចាប់ពី១០នាក់ឡើងទៅ ។ នៅឆ្នាំ១៩៧៨ ទីតាំងសម្លាប់ព្រៃស្វឹកនេះមានសមមិត្តភ័ណ ជាប្រធាន និងសមមិត្ត សំអេនជាអនុប្រធាន ។ នៅឆ្នាំ១៩៨០ រណ្តៅទាំងនោះត្រូវបានជីកឡើងដោយកម្លាំងរបស់កងទ័ពវៀតណាម និងប្រជាជនខ្មែរ ។ មានអដ្ឋិធាតុចំនួនបីរទេះគោត្រូវបានដឹកយកទៅថែរក្សានៅវត្តជ្រៃធំ ហើយដឹកបន្តទៅដាក់នៅវត្តកំពង់ត្រាច ព្រោះនៅវត្តជ្រៃធំមិនអាចរក្សាបានហ្មត់ចត់ ។ គ្រាន់តែលលាដ៍ក្បាលដែលគាស់បានមានចំនួនជាង ៣០០ក្បាល ដោយមិនគិតពីលលាដ៍ក្បាលនៅក្នុងដីសព្វ ថ្ងៃដែលមិនទាន់បានគាស់ ។

---